

Khmer Story Lovers

# ស្រីតូចត្រមែ

ស្រីតូចត្រមែ   ដើរតាមភ្លឺស្រែស្រងែបាំងបាត់   បងខំដើរស្កាត់   សុំស្លាមួយម៉ាត់
អូនដាច់មេត្តា   ពិតមែនហើយ   អូនដាច់មេត្តា។

ស្លាបងពេញថ្នក់   ម្ដេចមកកុហកថាបងអត់មានស្លា
ស្លានៅត្រង់ណា   សូមកែវជីវ៉ាបង្ហាញគេផង   ពិតមែនហើយ   បង្ហាញគេផង។

ជាតិជាមនុស្សខិល   របិលរប៉ូចគ្មាននរណាដូចបង   ស្លាលាក់ក្រោយខ្នង
អញ្ជើញប្រុសបង   យកចេញឆាប់រ៉ា   ពិតមែនហើយ   យកចេញឆាប់រ៉ា។

ស្លាបងមានពិត   តែចិត្តរៀមប៉ងចង់តែសូមស្នេហា
ស្នេហ៍នរសុំស្លា   ខ្ញុំមិនត្រូវការ   សុំលាសិនហើយ
ពិតមែនហើយ   សុំលាសិនហើយ។

*សិល្បករ : ស៊ិន ស៊ីសាមុត និង រស់ សេរីសុទ្ធា*

